Empowered lives.
Resilient nations.

# MEDIA ADVISORY

## ផ្តួចផ្តើមនវានុវត្តន៍ក្នុងវិស័យសាធារណៈ

### សិក្ខាសាលាថ្នាក់ជាតិស្តីពីវិស័យសាធារណៈក្នុងយុគសម័យឌីជីថល

ក្រោមឥទ្ធិពលនៃបដិវត្តន៍ឧស្សាហកម្មទីបួន នវានុវត្តន៍ក្នុងវិស័យសាធារណៈ លែងជាអ្វីដែលធ្វើឱ្យវិស័យនេះមានភាពប្រណិតទៀតហើយ ប៉ុន្តែជាអ្វីដែលរដ្ឋាភិបាលក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកចាំបាច់ត្រូវតែធ្វើដើម្បីបន្តរៀបចំខ្លួន និងចូលរួមប្រកួតប្រជែងក្នុងសតវត្សរ៍ទី២១។ ការផ្លាស់ប្តូរនេះបានកំពុងធ្វើឱ្យមានការរំពឹងចង់បាននូវសេវាសាធារណៈដែលកាន់តែមានភាពច្នៃប្រឌិតថ្មីជាងមុន និងផ្តល់ទាន់ពេលវេលាជាងមុន។ កម្ពុជាគឺជាប្រទេសមួយ ក្នុងចំណោមប្រទេសជាច្រើន ដែលមានសេដ្ឋកិច្ចកំពុងរីកចម្រើនយ៉ាងឆាប់រហ័សនៅក្នុងតំបន់ដែលត្រូវតែត្រៀមខ្លួនទប់ទល់ជាមួយនឹងការផ្លាស់ប្តូរនេះ។

ក្រសួងមុខងារសាធារណៈ និង UNDP ប្រចាំប្រទេសកម្ពុជា សហការគ្នារៀបចំសិក្ខាសាលាថ្នាក់ជាតិមួយក្នុងគោលបំណងពិភាក្សាអំពីលទ្ធភាពជម្រុញឱ្យមាននវានុវត្តន៍ក្នុងវិស័យអភិបាលកិច្ច ដែលជាកិច្ចខិតខំប្រឹងប្រែងធ្វើឱ្យការផ្តល់សេវាដល់ប្រជាពលរដ្ឋកាន់តែល្អប្រសើរជាងមុន។

សិក្ខាសាលានេះ នឹងផ្តល់នូវវេទិកាឱ្យអ្នកចូលរួមបានស្វែងយល់ពីលទ្ធភាពយកបច្ចេកវិទ្យាឌីជីថលមកប្រើប្រាស់ក្នុងវិស័យសាធារណៈដើម្បីជួយកម្ពុជាឱ្យសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ពង្រឹងការជឿទុកចិត្តរបស់ប្រជាពលរដ្ឋលើប្រព័ន្ធអភិបាលកិច្ច និងផ្តល់សេវាសាធារណៈឱ្យកាន់តែមានប្រសិទ្ធភាព។

**សិក្ខាសាលា៖** **សិក្ខាសាលាថ្នាក់ជាតិស្តីពីវិស័យសាធារណៈក្នុងយុគសម័យឌីជីថល**

**អ្នកចូលរួម៖** **ឯកឧត្តម កិត្តិបណ្ឌិត ពេជ្រ ប៊ុនធិន** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ លោក Nick Beresford អ្នកតំណាងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិនៅកម្ពុជា អ្នកជំនាញអន្តរជាតិ និងមន្ត្រីរាជការជាង ៣០០ នាក់ផ្សេងទៀត

**កាលបរិច្ឆេទ៖** ថ្ងៃច័ន្ទ ទី០៤ ខែមីនា ឆ្នាំ២០១៩ ចាប់ពីម៉ោង ០៨:30 ព្រឹក

**ទីកន្លែង៖** សាលាភូមិន្ទរដ្ឋបាល រាជធានីភ្នំពេញ

# SPARKING INNOVATION IN THE PUBLIC SECTOR

## National Conference on Public Sector in the Digital Era

With the advent of the Fourth Industry Revolution (IR4.0), the need for public sector innovation is no longer a luxury but a must for governments in Asia and the Pacific to stay equipped and competitive in the 21st century. The transformation caused by the IR4.0 is raising expectations for more innovative and timely public services. The Royal Government of Cambodia is one of the emerging economies in the region preparing to deal with these changes.

The Ministry of Civil Service (MCS) and the UN Development Programme (UNDP) in Cambodia have teamed up to hold a national conference to look at how to advance innovation in governance, in an effort to improve services to citizens.

The conference will provide a platform for participants to explore possibilities to adapt digital technologies within the public sector to support the Royal Government of Cambodia to achieve Cambodia's Sustainable Development Goals (CSDGs), strengthen citizens' trust in the government system, and deliver pubic service more efficiently.

| | |
|---|---|
| **WHAT** | **National Conference on Public Sector in the Digital Era** |
| **WHO** | **H.E. Ketebandith Pech Bunthin** (Minister of Civil Service), **Nick Beresford** (UNDP Resident Representative), innovation experts and more than 300 civil servants |
| **WHEN** | 04 March 2019, 08:30 am to 05:30 pm |
| **WHERE** | Royal School of Administration, Phnom Penh |

*For more information and media requests, please contact Mr. Samruol Im at samruol.im@undp.org or visit https://bit.ly/2TkCi5e.*

***Follow us on social media:*** *Facebook Twitter LinkedIn Instagram*